រឿងខ្លី

# ប៊ិច ខ្មៅដៃ និង សៀវភៅ

ណារិនមិនចូលចិត្តការរៀនសូត្រទេ ប៉ុន្តែម្តាយរបស់គេបានអោយគេទៅរៀននៅសាលាបឋមសិក្សា ។ រាល់ថ្ងៃ ណារិនទៅសាលាអោយផុតពីផ្ទះតែប៉ុណ្ណោះ គេមិនបានចូលរៀនឡើយ ។ គេទៅលេងគប់វង់ លេងលោតអន្ទាក់ រឺលេងល្បែងផ្សេងៗទៀតជាមួយក្មេងៗក្នុងភូមិ ។ ព្រឹកនេះ នៅពេលដែលណារិនកំពុងលេងគប់វង់ ចរិយាដែលជាមិត្តរួមថ្នាក់បានដើរមកឃើញ ក៏ដើរទៅជិតហើយសួរ “ណារិនមកទៅរៀន !”





ណារិនគ្រវីក្បាលហើយនិយាយ “មិនទៅរៀនទេនៅលេងវិញសប្បាយជាង ! ” ។ ណារិនឆ្លើយទៅចរិយាតែប៉ុណ្ណឹង ហើយក៏លេងគប់វង់បន្តទៀត ។ ចរិយាដើរទៅសាលារៀនតែម្នាក់ឯង ។ ក្រោយពេលលេងគប់វង់អស់ចិត្ត ដល់ម៉ោងដែលសិស្សចេញពីសាលា ណារិនក៏ត្រលប់ទៅផ្ទះវិញ ។ ពេលទៅដល់ផ្ទះណារិនលប